# សេចក្តីប្រកាសព័ត៌មាន

## ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១

## ស្ថានទូតជប៉ុននិងកម្មវិធីស្បៀងអាហាពិភពលោកធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលសុវត្ថិភាពដែលសាងសង់ថ្មី និង កម្មវិធីផ្តល់អាហារដល់សាលារៀននៅខេត្តកំពង់ធំ

ថ្ងៃទី២៦ ខែមករា នៅខេត្តកំពង់ធំ។ស្ថានទូតជប៉ុននិងកម្មវិធីស្បៀងអាហាពិភពលោកនឹងធ្វើបេសកកម្មរួមគ្នាមួយទៅកាន់ខេត្តកំពង់ធំ ដើម្បីសង្កេតមើលការបន្តការផ្តល់អាហារដល់សាលារៀន និងទៅពិនិត្យមើលមជ្ឈមណ្ឌលសុវត្ថិភាពដែលសាងសង់ថ្មី។

កម្មវិធីទាំងនេះត្រូវបានអនុវត្តក្នុងភាពជាដៃគូរៀងៗខ្លួនជាមួយក្រសួងអប់រំ យុវជន និង កីឡា និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដែលជាការត្រៀមសង្គ្រោះបន្ទាន់ ដែលបង្ហាញនូវភាពជាដៃគូយូរអង្វែងរវាងរដ្ឋាភិបាលជប៉ុននិងកម្មវិធីស្បៀងអាហារពិភពលោក ក្នុងការគាំទ្រដល់អតីតភាពជាតិនៅក្នុងវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភក៏ដូចជាការត្រៀមរៀបចំគ្រាមានអាសន្ន។

ឯកអគ្គរដ្ឋទូតជប៉ុន Masahiro Mikami បានកត់សម្គាល់ថា កម្មវិធីស្បៀងអាហាពិភពលោក និងជប៉ុនបានធ្វើការជាមួយគ្នាអស់រយៈពេលជាច្រើនឆ្នាំមកហើយ ដើម្បីលុបបំបាត់ភាពអត់ឃ្លាន និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ហើយលោកទន្ទឹងរង់ចាំដំណើរទស្សនៈកិច្ចនេះ។

ចាប់តាំងពីឆ្នាំ១៩៩៨មក រដ្ឋាភិបាលជប៉ុនគឺជាដៃគូដ៏សំខាន់មួយសម្រាប់ការងាររបស់កម្មវិធីស្បៀងអាហាពិភពលោកនៅកម្ពុជា ដោយបានចូលរួមវិភាគទានចំនួន ២២លានដុល្លាអាមេរិក ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ

តាមរយៈជំនួយ (អង្ករ និងត្រីខកំប៉ុង) និងវិភាគទានជាសាច់ប្រាក់ក្នុងការគាំទ្រសន្តិសុខស្បៀង និងអាហាររូបត្ថម្ភ រួមមាន ការផ្តល់ចំណីអាហារនៅសាលារៀន ក៏ដូចជាការត្រៀមនិងការឆ្លើយតបបន្ទាន់។

ការផ្តល់អាហារនៅសាលារៀន ផ្តល់នូវអាហារប្រកបដោយសុវត្ថិភាព និងជីវជាតិដល់កុមារថ្នាក់ត្រៀមចូលបឋមសិក្សា និងបឋមសិក្សានៅក្នុងសហគមន៍ដែលងាយរងគ្រោះ។ វាលើកទឹកចិត្តឱ្យកុមារចុះឈ្មោះចូលរៀន និងចូលរៀនជាប្រចាំ រួមទាំងកាត់បន្ថយភាពអត់ឃ្លានរយៈពេលខ្លី ធ្វើអោយប្រសើរឡើងនូវការផ្តោតអារម្មណ៍ក្នុងអំឡុងពេលសិក្សា ដូច្នេះវារួមចំណែកដល់លទ្ធផលនៃការអប់រំ និងអាហាររូបត្ថម្ភ ខណៈពេលដែលវាដើរតួជាបណ្តាញសុវត្ថិភាពដ៏សំខាន់សម្រាប់គ្រួសារដែលងាយរងគ្រោះបំផុត។

នៅឆ្នាំ២០១៩ ជប៉ុនបានចូលរួមវិភាគទានចំនួន ២.៧ លានដុល្លាអាមេរិកដល់កម្មវិធីស្បៀងអាហាពិភពលោក ដើម្បីលើកកម្ពស់ភាពធន់របស់សហគមន៍កម្ពុជាក្នុងការរងនូវភាពតក់ស្លុត និងកសាសមត្ថភាពស្ថាប័នក្នុងការត្រៀមលក្ខណៈបន្ទាន់។ ការគាំទ្រនេះបានជួយឱ្យមាន ១) សាងសង់មជ្ឈមណ្ឌលជម្លៀសដែលមានសុវត្ថិភាពចំនួន៦ នៅក្នុងខេត្តចំនួន៣ដែលជាខេត្តដែលងាយរងគ្រោះដោយទឹកជំនន់។ ២) ពង្រឹងការគ្រប់គ្រង ផែនការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសហគមន៍ និងទី៣) ពង្រឹងសកម្មភាពមុនពេល តាមរយៈប្រព័ន្ធប្រកាសអាសន្ន។

តំណាងកម្មវិធីស្បៀងអាហារពិភពលោក អ្នកស្រី Claire Conan បានកត់សម្គាល់ថា គ្រោះទឹកជំនន់ធ្ងន់ធ្ងរដែលបានប៉ះពាល់ដល់ប្រជាជនជាង៨00,000នាក់នៅទូទាំងខេត្តចំនួន១៩ កាលពីខែតុលាគឺជាកាត់សម្គាល់ដ៏សំខាន់មួយ អំពីសារៈសំខាន់នៃការខិតខំរួមគ្នារបស់យើងក្នុងការរៀបចំ និងឆ្លើយតបចមពោះគ្រោះមហន្តរាយ។ ការគាំទ្ររបស់រដ្ឋាភិបាលជប៉ុនក្នុងការកសាងមជ្ឈមណ្ឌលជម្លៀសដែលមានសុវត្ថិភាពចំនួន៦ និង បង្កើនការត្រៀមរៀបចំជាបន្ទាន់នៅកម្រិតសហគមន៍ គឺជាចំណុចសំខាន់ក្នុងការជួយសង្គ្រោះជីវិត និងការរស់នៅក្នុងប្រទេសកម្ពុជា។

បេសកកម្មនេះនឹងធ្វើដំណើរទៅកាន់សាលាបឋមសិក្សាជីមាក ខេត្តកំពង់ធំដើម្បីសង្កេតមើលកម្មវិធីផ្តល់អាហារដល់សាលារៀន និងធ្វើដំណើរទៅកាន់ឃុំដែលងាយលិចទឹកក្នុងឃុំខ្សាច់ជីរួស ដើម្បីមើលមជ្ឈមណ្ឌលជម្លៀសមួយក្នុងចំណោមមជ្ឈមណ្ឌលជម្លៀសទាំង៦ដែលកំពុងសាងសង់។

---

សម្រាប់ព័ត៏មានបន្ថែម សូមទាក់ទង អ្នកស្រី ជា ជូ មន្ត្រីផ្នែកទំនាក់ទំនង និងធ្វើរបាយការណ៍នៃកម្មវិធីស្បៀងអាហារពិភពលោក

តាមរយៈទូរស័ព្ទ:+855 78 565 283 or Email: chou.chea@wfp.org

ចំពោះរូបថត និងសម្រង់ព័ត៏មានបន្ថែមទៀតនឹងផ្តល់ជូននៅថ្ងៃបន្ទាប់ពីព្រឹត្តិការណ៍នេះ